# ជំពូកទី ៨
# ផែនការគ្រប់គ្រងបរិស្ថាន( ផ.គ.ប )

Draft

Draft

# ជំពូកទី៨

# ផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប)

## ៨.១ សេចក្តីផ្តើម

**១.** ផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប) ត្រូវអនុវត្តន៍សំរាប់គម្រោងអភិវឌ្ឍន៍ទាំងឡាយ ដែលបណ្តាលឱ្យមានហេតុប៉ះពាល់បរិស្ថានអវិជ្ជមានទោះនៅក្នុងទ្រង់ទ្រាយណាក្តី ដល់ធនធានធម្មជាតិ និងធនធានសង្គម ដែលទទួលរងនូវការប៉ះពាល់ទាំងនៅក្នុង និងជុំវិញគម្រោង ។ ដូច្នេះផែនការគ្រប់គ្រងបរិស្ថានគឺជាដំណើរការមួយត្រូវតែមានជាចាំបាច់នៅក្នុងគ្រប់ដំណាក់កាលរបស់គម្រោង សំរាប់ត្រួតពិនិត្យ និងកាត់បន្ថយ ឬទប់ស្កាត់នូវរាល់ហេតុប៉ះពាល់អវិជ្ជមានទាំងអស់ ដែលនឹងអាចកើតមានឡើងដោយសារសកម្មភាពនានារបស់គម្រោង ។

**២.** គម្រោងវិនិយោគដាំដើមកៅស៊ូរបស់ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក (អេស ប៊ី ខេ)** នេះ នឹងបណ្តាលឱ្យមានហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គម ដែលបង្កឡើងដោយសារសកម្មភាពគម្រោងក្នុងគ្រប់ដំណាក់កាលរបស់គម្រោង ។ ការអនុវត្តន៍ ផ.គ.ប នេះជាភារកិច្ចរបស់ក្រុម ឬផ្នែកបរិស្ថានដែលនឹងត្រូវបង្កើតឡើង និងអនុវត្តដោយម្ចាស់គម្រោងផ្ទាល់ ដោយសហការណ៍ជាមួយស្ថាប័នជំនាញពាក់ព័ន្ធ ហើយត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីក្រសួងបរិស្ថាន ដើម្បីកំណត់ទំហំនិងកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថាននានា ដែលអាចនឹងកើតមានឡើងដោយសារសកម្មភាពវិនិយោគ ។

## ៨-២ សមាសភាពនៃក្រុមត្រួតពិនិត្យ និងការឃ្លាំមើលវិធានការកិច្ចការពារបរិស្ថាន

**៣.** សមាសភាពនៃក្រុមត្រួតពិនិត្យនេះ មានសមាជិកចំរុះមកពីស្ថាប័នជំនាញពាក់ព័ន្ធដូចតទៅ:

១- មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន របស់ក្រសួងបរិស្ថាន

២- មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នៃក្រសួងបរិស្ថាន

៣- មន្ត្រីជំនាញតំណាងឱ្យមន្ទីរបរិស្ថាន ខេត្តក្រចេះ

៤- មន្ត្រីជំនាញតំណាងឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៥- មន្ត្រីជំនាញតំណាងឲ្យរដ្ឋបាលព្រៃឈើ

៦- មន្ត្រីជំនាញតំណាងឲ្យរដ្ឋបាលជលផល

៧- អ្នកតំណាងឱ្យក្រុមហ៊ុន

៨- អាជ្ញាធរដែនដីមូលដ្ឋានខេត្តក្រចេះ

៩- ប្រជាជនមូលដ្ឋានក្នុងតំបន់គម្រោង

បញ្ជាក់: សមាសភាពមន្ត្រីទាំងអស់នេះ នឹងត្រូវផ្តល់តួនាទី និងមុខងារក្រោមការចង្អុលបង្ហាញពីក្រសួងបរិស្ថាន។

## ៨-៣ ផែនការគ្រប់គ្រងបរិស្ថាន

### ៨-៣-១ វិធានការការពារបរិស្ថាន

៤. យោងតាមអនុក្រឹត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងយោងតាមលទ្ធផលនៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គម ដែលបង្កឡើងដោយសារសកម្មភាពនៅគ្រប់ដំណាក់កាលរបស់គម្រោង ដូចបានរៀបរាប់នៅក្នុងជំពូកខាងដើមនេះ ម្ចាស់គម្រោងនឹងរៀបចំកំណត់នូវវិធានការសំខាន់ៗមួយចំនួនសំរាប់ធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានានូវការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះដោយប្រសិទ្ធិភាព ស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថាន ព្រមទាំងធានាឱ្យមានចីរភាពនៃគម្រោងអភិវឌ្ឍន៍ ដែលក្នុងនោះម្ចាស់គម្រោងនឹង ៖

- រៀបចំក្រុម ឬផ្នែកបរិស្ថានសំរាប់ការអនុវត្តន៍ផែនការនេះ
- រៀបចំផែនការសកម្មភាពការងារឱ្យបានច្បាស់លាស់ក្នុងកិច្ចការពារបរិស្ថាន
- បំពាក់ឧបករណ៍ការពារសុខភាព គ្រោះថ្នាក់ និងគ្រឿងចក្រទំនើបៗតាមបែបផែនបច្ចេកទេស
- ការពារគ្រោះថ្នាក់ដោយយថាហេតុពីសកម្មភាពគម្រោងទៅលើធនធានធម្មជាតិ និងសង្គម
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំង-បច្ចេកទេស និងទទួលយកនូវការកែប្រែបច្ចេកទេសណាមួយដែលជំនាញតំរូវអោយធ្វើ។

### ៨-៣-២ កម្មវិធីបំពាក់បំប៉ន

៥. កម្មវិធីបំពាក់បំប៉នក៏ជាកត្តាសំខាន់មួយនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដែលគម្រោងត្រូវយកចិត្តទុកដាក់ ដើម្បីអនុវត្តផែនការមេរបស់គម្រោងបានជោគជ័យ ។ ដើម្បីធ្វើឱ្យគម្រោងវិនិយោគនេះមានការអភិវឌ្ឍន៍ ប្រកបដោយស្ថេរភាពនោះ ចាំបាច់ត្រូវមានធនធានមនុស្ស ដែលមានសមត្ថភាពគ្រប់គ្រាន់សំរាប់បំពេញការងារឱ្យបានរីកចំរើនទាំងការងារបច្ចេកទេស និងការងារបរិស្ថាន។ ដូច្នេះ ម្ចាស់គម្រោងនឹងរៀបចំឱ្យមានវគ្គអប់រំបំពាក់បំប៉ន ដល់បុគ្គលិក និងកម្មករមានដូចជា ៖

- ចំណេះដឹងបច្ចេកទេសដាំដុះ និងការបញ្ជាគ្រឿងម៉ាស៊ីនគ្រប់ប្រភេទក្នុងពេលដំណើរការអាជីវកម្ម
- ចំណេះដឹងពីការការពារសុវត្ថិភាព ពេលកំពុងបំពេញការងាររបស់គម្រោង
- អប់រំដល់កម្មករឱ្យពាក់ឧបករណ៍ការពារសុខភាពពេលកំពុងធ្វើការងារ
- បំពាក់បំប៉ន និង ផ្សព្វផ្សាយពីជំនាញបច្ចេកទេស ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ
- អប់រំ និងផ្សព្វផ្សាយពីវិធីសាស្ត្រការពារជម្ងឺគតត្បាតផ្សេងៗ ជាពិសេសជម្ងឺអេដស៍ គ្រុនចាញ់ គ្រុនផ្តាសាយបក្សី ដែលមាននៅក្នុងតំបន់គម្រោង
- ធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំអំពីប្រភេទឈើ និង ពពួកសត្វកម្រដែលត្រូវអភិរក្ស
- ធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំអំពីសារៈប្រយោជន៍នៃព្រៃឈើ និងសត្វព្រៃ
- ធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំអំពីវិធីសាស្ត្រការពារសុខភាព-សុវត្ថិភាព
- ត្រៀមថវិកាបំរុងទុក សំរាប់ប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន ។

## ៨-៣-៣ កម្មវិធីត្រួតពិនិត្យបរិស្ថាន

**៦.** កម្មវិធីត្រួតពិនិត្យបរិស្ថាននេះ មានបំណងសំខាន់ គឺដើម្បីកំណត់ទំហំ និងប្រៀបធៀបឱ្យដឹងថាៈ រវាងហេតុប៉ះពាល់បរិស្ថាន រឺជានការកាត់បន្ថយនូវហេតុប៉ះពាល់អវិជ្ជមានដែលបានសិក្សាទាំងនោះ ហើយ នឹងលទ្ធផលនៃការងារត្រួតពិនិត្យបរិស្ថាននៅក្នុងតំបន់គម្រោងជាក់ស្តែង នៅគ្រប់ដំណាក់កាលរបស់គម្រោង តើវាអាចធានាបាននូវចីរភាពបរិស្ថានដែរឬទេ?

**៧.** ការត្រួតពិនិត្យបញ្ហាបរិស្ថាននឹងត្រូវអនុវត្តដោយម្ចាស់គម្រោង នៅគ្រប់ដំណាក់កាលនៃគម្រោង ហើយលទ្ធផលនៃការត្រួតពិនិត្យនេះ ក្រុមហ៊ុននឹងធ្វើរបាយការណ៍ផ្ញើរជូនក្រសួងបរិស្ថានរាល់ ០៣ ខែ/ម្តង ដើម្បីវាយតំលៃពីសកម្មភាពគម្រោង ហើយនិងចុះអង្កេតតាមដានសំរាប់កែលំអក្នុងកិច្ចដំណើរការរបស់ គម្រោង ទៅតាមបទពិសោធន៍-បច្ចេកទេស និងបញ្ចៀសបាននូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមានធ្ងន់ធ្ងរឱ្យ ដល់កំរិតអប្បបរមា។ ចំណែកហេតុប៉ះពាល់វិជ្ជមានក្រុមហ៊ុននឹងខិតខំធ្វើការកែច្នៃឱ្យបានប្រសើរថែមទៀត។ ក្នុងករណីពិសេសណាមួយ ដែលបង្កឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិ និងបរិស្ថានសង្គម ដោយសារ សកម្មភាពគម្រោង ក្រុមហ៊ុននឹងអញ្ជើញមន្ត្រីជំនាញនៃក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ ដើម្បីចុះអង្កេត និងធ្វើការកែលំអ ។

**៨.** កម្មវិធីត្រួតពិនិត្យបញ្ហាបរិស្ថានសំខាន់ៗ នៅគ្រប់ដំណាក់កាលរបស់គម្រោងនេះម្ចាស់គម្រោងនឹង ធ្វើការត្រួតពិនិត្យលើបញ្ហាបរិស្ថានសំខាន់ៗមួយចំនួនមាន ៖

### ១- ដំណាក់កាលមុនប្រតិបត្តិគម្រោង

**៩.** នៅដំណាក់កាលនេះ ក្រុមការងារនឹងធ្វើការត្រួតពិនិត្យទៅលើធនធានធម្មជាតិសំខាន់ៗមួយចំនួន ដែលនឹងអាចទទួលរងនូវឥទ្ធិពលអាក្រក់ពីសកម្មភាពគម្រោង មានដូចជាៈ សណ្ឋានដី គុណភាពខ្យល់ ប្រព័ន្ធជលសាស្ត្រ សំលេង-រំញ័រ ព្រៃឈើ សត្វព្រៃ មុខរបរ និងការរស់នៅរបស់សហគមន៍ពាក់ព័ន្ធ ។

### ២- ដំណាក់កាលប្រតិបត្តិគម្រោង

**១០.** ការងារសំរាប់ការត្រួតពិនិត្យបរិស្ថាននៅក្នុងដំណាក់កាលនេះ ជាការងារសំខាន់ជាងដំណាក់កាល ផ្សេងៗទៀត ដែលសកម្មភាពគម្រោងអាចបង្កអោយប៉ះពាល់ដល់ធនធានធម្មជាតិសំខាន់ៗ ក្នុងតំបន់នោះ ក្នុងរយៈពេលវែង។ ដូចនេះ ទិសដៅសំខាន់នៃការត្រួតពិនិត្យគឺផ្តោតទៅលើធនធានសំខាន់ៗមានដូចជាៈ សណ្ឋានដី គុណភាពដី គុណភាពទឹក ប្រព័ន្ធជលសាស្ត្រ គុណភាពខ្យល់ សត្វព្រៃ ព្រៃឈើ សំលេង-រំញ័រ ជីវៈចំរុះក្នុងទឹក ការគ្រប់គ្រងសំណល់រឹង-រាវ ហេដ្ឋារចនាសម្ព័ន្ធ ទំនៀមទំលាប់ប្រពៃណី និងសុខភាព សាធារណៈ។ល។

### ៣- ដំណាក់កាលបញ្ចប់គម្រោង

**១១.** នៅដំណាក់កាលនេះ ក្រុមការងារនឹងត្រួតពិនិត្យលើធនធានធម្មជាតិសំខាន់ៗមួយចំនួនដូចជាៈ ការប្រើប្រាស់ដី គុណភាពទឹក-ដី ជីវចំរុះក្នុងទឹក ព្រមទាំងមុខរបរនិងការរស់នៅ និងហេដ្ឋារចនាសម្ព័ន្ធ។

Draft

តារាង៨-១៖ កម្មវិធីត្រួតពិនិត្យបរិស្ថាន

| ល.រ | ធនធានបរិស្ថាន | ការត្រួតពិនិត្យ | ស្ថាប័នត្រួតពិនិត្យ | ខួបនៃការត្រួតពិនិត្យ |
|---|---|---|---|---|
| ១-ធនធានរូបសាស្ត្រ | | | | |
| ក | សណ្ឋានដី | - ការរៀបចំព្រំទីតាំងគម្រោង<br>- ការឈូសឆាយផ្លូវចេញ-ចូលការដ្ឋាន<br>- ការរៀបចំការដ្ឋានស្នាក់នៅ និងការដាំកូនកៅស៊ូ នៅតាមអនុតំបន់នីមួយៗ ។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោង រយៈពេល ០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោង រយៈពេល០១ដង |
| ខ | ការហូរច្រោះ និងគុណភាពដី | - ការរៀបចំព្រំទីតាំងគម្រោង<br>- ការឈូសឆាយផ្លូវចេញ-ចូលការដ្ឋាន<br>- ការរៀបចំកាដ្ឋានស្នាក់នៅ និងការដាំដុះនៅតាមអនុតំបន់នីមួយៗ<br>- ការប្រើប្រាស់យានដ្ឋានជួសជុលគ្រឿងចក្រ<br>- កន្លែងទុកដាក់និងគ្រប់គ្រងសំណល់គ្រប់ប្រភេទ ។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោងរយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោងរយៈពេល០១ដង |
| គ | ប្រព័ន្ធជលសាស្ត្រ និងគុណភាពទឹក | - ការដ្ឋានឈូសឆាយ<br>- ការរៀបចំការដ្ឋានស្នាក់នៅ និងការដាំដុះកូនកៅស៊ូ នៅតាមអនុតំបន់នីមួយៗ<br>- កន្លែងគ្រប់គ្រងសំណល់។<br>- ផ្ទៃដីព្រៃដែលត្រូវរក្សាទុកនៅតាមប្រភពទឹក និងប្រភពទឹកពាក់ព័ន្ធ<br>- កន្លែងស្តុក និងប្តូរប្រេងគ្រឿងចក្រ។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងធនធានទឹក និងឧតុនិយម<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោង រយៈពេល០១ដង |

| | | | | |
|---|---|---|---|---|
| ឃ | គុណភាពខ្យល់ | - ការដ្ឋានឈូសឆាយ<br>- ការរៀបចំការដ្ឋានស្នាក់នៅ និងការដាំកូនកៅស៊ូនៅតាមអនុតំបន់នីមួយៗ<br>- ប្រភពបញ្ចេញឧស្ម័នពុល។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- ក្រសួងរ៉ែ និងថាមពល<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោង រយៈពេល០១ដង |
| ង | សំលេង-រំញ័រ | - គ្រឿងចក្រគ្រប់ប្រភេទ<br>- ពេលវេលាធ្វើការ<br>- បរិមាណ និងគុណភាពគ្រឿងចក្រ។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោង រយៈពេល០១ដង |
| **២-ធនធានជីវសាស្ត្រ** | | | | |
| ក | ព្រៃឈើ និងជម្រកសត្វព្រៃ | - ស្ថានភាពនិងបរិមាណព្រៃឈើក្នុងតំបន់គម្រោង<br>- ផ្ទៃដីព្រៃដែលរក្សាទុកតាមដងប្រភពទឹកនានា និងតំបន់ភ្នំ<br>- អនុតំបន់នីមួយៗ និងប្រព័ន្ធផ្លូវការពារភ្លើងឆេះព្រៃ ។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោងរយៈពេល០១ដង |
| ខ | ជីវចម្រុះក្នុងទឹក | - ផ្ទៃដីតំបន់ព្រៃ នៅតាមប្រភពទឹកនានា និងតំបន់ភ្នំ ក្នុងតំបន់គម្រោង<br>- កន្លែងគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោង រយៈពេល០១ដង |
| **៣-ធនធានសេដ្ឋកិច្ច-សង្គម** | | | | |
| ក | មុខរបរ និងការរស់នៅរបស់សហគមន៍មូលដ្ឋាន | - ការតាំងទីលំនៅ<br>- ជីវភាពរស់នៅរបស់សហគមន៍<br>- ទីគោរពបូជារបស់ប្រជាពលរដ្ឋ ។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោង រយៈពេល០១ដង |

| | | | | |
|---|---|---|---|---|
| ខ | ការប្រើប្រាស់ទឹក | - ពិនិត្យប្រភព និងបរិមាណប្រើប្រាស់ទឹក<br>- ពិនិត្យគុណភាពទឹក ។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>- ក្រសួងធនធានទឹក និងឧតុនិយម<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោង រយៈពេល០១ដង |
| គ | សុខភាពនិង សុខមាលភាព សាធារណៈ | - ទីកន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករ និងសហគមន៍<br>- ឧបករណ៍សុវត្ថិភាព និងស្លាកសញ្ញា<br>- សុខភាពរបស់បុគ្គលិក-កម្មករ និង សហគមន៍ ។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- មណ្ឌលសុខភាពក្បែរ/ក្នុង តំបន់គម្រោង<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោង រយៈពេល០១ដង |
| ឃ | ហេដ្ឋារចនាសម្ព័ន្ធ | - ស្ពាន ផ្លូវពាក់ព័ន្ធ ទម្ងន់ផ្ទុករបស់យានយន្ត ពេលដឹកឧបករណ៍ សម្ភារៈ និងផលិតផល ចេញ-ចូល ។ | - ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថាន ខេត្តក្រចេះ<br>- អាជ្ញាធរមូលដ្ឋាន<br>- ក្រុមហ៊ុនវិនិយោគ ។ | - ដំណាក់កាលមុនប្រតិបត្តិគម្រោងរយៈពេល០១ខែម្តង<br>- ដំណាក់កាលប្រតិបត្តិគម្រោង រយៈពេល០៣ខែម្តង<br>- ដំណាក់កាលបញ្ចប់គម្រោង រយៈពេល០១ដង |

## ៨-៣-៤ គម្រោងថវិកាសំរាប់ការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន

**១២.** ចាប់ពីឆ្នាំ ២០១៥តទៅ ក្រុមហ៊ុនបានគ្រោងថវិកាសរុបចំនួន ៣៤.000.00ដុល្លារអាមេរិកក្នុងមួយឆ្នាំៗ សម្រាប់អនុវត្តន៍**ផែនការគ្រប់គ្រងបរិស្ថាន** ដែលមានរយៈពេលស្មើនឹងអាយុកាលនៃការធ្វើវិនិយោគកំណត់ដោយច្បាប់ និងប្រើសម្រាប់: (១) គ្រប់គ្រងតំបន់ទ្រនាប់ចំនួន ១០.៨00,00ដុល្លារអាមេរិក (២) អនុវត្តន៍កម្មវិធីត្រួតពិនិត្យ និងវាយតម្លៃចំនួន ២៣.២00,00ដុល្លារអាមេរិក។ ដោយឡែកចំពោះថវិកាបំរុង សម្រាប់ឧបត្ថម្ភសមាជិកគ្រួសារប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងបុគ្គលិកកម្មករដែលមានគ្រោះថ្នាក់ដោយចៃដន្យនៅក្នុងរយៈពេលប្រតិបត្តិការ មិនបានដាក់បញ្ចូលទៅក្នុងតារាងតម្លៃប៉ាន់ស្មាន និងតាមដានពិនិត្យវាយតម្លៃនេះទេ។ ប៉ុន្តែ ក្រុមហ៊ុនត្រូវមានថវិកាបំរុងគ្រប់គ្រាន់សំរាប់គំរោងថវិកានេះ នៅក្នុងករណីនៃឧបទ្ទវហេតុ (សូមមើល **តារាង ៨-២**)។

**តារាង ៨-២៖ តម្លៃសរុបសម្រាប់ការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន ការត្រួតពិនិត្យ និងវាយតម្លៃ**

| កម្មវិធី | សកម្មភាព | ចំនួន | តម្លៃ (ដុល្លារ) | |
|---|---|---|---|---|
| | | | ឯកតា | សរុប/ឆ្នាំ |
| គ្រប់គ្រងតំបន់ទ្រនាប់ | អ្នកល្បាត | ០៦នាក់/៣ស្ថានីយ៍ | ១៥០/ខែ | ១០.៨០០ |
| | សរុប | | | ១០.៨០០ |
| ការត្រួតពិនិត្យ | អ្នកសម្របសម្រួលបរិស្ថាន (LEC) | ០១ | ៣០០/ខែ | ៣.៦០០ |
| | សេវាកម្មត្រួតពិនិត្យ (ក្រសួងបរិស្ថាន) | ០៣ខែម្តង | ១.៥០០ | ៦.០០០ |
| | សេវាកម្មត្រួតពិនិត្យ (ក្រសួងបរិស្ថាន និង គណៈកម្មការអន្តរក្រសួង) | ០៦ខែម្តង | ៥.០០០ | ១០.០០០ |
| | តេស្ត៍ | ០៦ខែម្តង | ១.៨០០ | ៣.៦០០ |
| | សរុប | | | ២៣.២០០ |
| | សរុបរួម | | | ៣៤.០០០ |

**១៣.** យោងតាមតារាង៨-២ខាងលើ ថវិកាសម្រាប់គ្រប់គ្រងតំបន់ទ្រនាប់ ក្នុង១ឆ្នាំៗមានចំនួន ១០.៨០០ ដុល្លាអាមេរិក។ សម្រាប់ឆ្នាំ ២០១៥ ក្រុមហ៊ុនដូទីសាយហ្គូន-ប៊ិញហ្វឿក (អេស ប៊ី ខេ) គ្រោងបែងចែកថវិកានេះជាពីរចំណែក៖ (១) ថវិកាចំនួន ៣.៦០០ដុល្លាសម្រាប់សាងសង់ប៉ុស្តិ៍យាមល្បាតចំនួន ០៣ស្ថានីយ (តម្លៃ ១.២០០ដុល្លា/ស្ថានីយ) ដែលដែលក្រុមហ៊ុនខ្លួនឯងជាអ្នកទទួលអនុវត្តន៍ ហើយនឹងសាងសង់ចប់សព្វគ្រប់ក្នុងរយៈពេល ០៤ខែដើមឆ្នាំ និង (២) ថវិកាចំនួន ៧.២០០ដុល្លាអាមេរិក សម្រាប់ផ្តល់បៀវត្សចំពោះអ្នកល្បាតចំនួន០៦នាក់ (០២នាក់ក្នុង០១ស្ថានីយ) សម្រាប់រយៈពេល០៨ខែចុងឆ្នាំ (១៥០ដុល្លារ/ខែ/ម្នាក់) (តារាង៨-៣)។ ចាប់ពីឆ្នាំ ២០១៦ តទៅជារៀងរាល់ឆ្នាំ ក្រុមហ៊ុនដូទីសាយហ្គូន-ប៊ិញហ្វឿក (អេស ប៊ី ខេ) គ្រោងនឹងផ្តល់ថវិកាចំនួន ១០.៨០០ដុល្លាអាមេរិក/ឆ្នាំនេះ ជាប្រាក់បៀវត្សចំពោះអ្នកល្បាតចំនួន០៦នាក់ (១៥០ដុល្លារអាមេរិក/ខែ/ម្នាក់)។



Draft

**តារាង ៨-៣៖ តម្លៃសរុបសម្រាប់គ្រប់គ្រងតំបន់ទ្រនាប់ក្នុងឆ្នាំ២០១៥**

| កម្មវិធី | សកម្មភាព | ចំនួន | តម្លៃ (ដុល្លារ) | |
|---|---|---|---|---|
| | | | ឯកតា | សរុប/ឆ្នាំ |
| គ្រប់គ្រងតំបន់ទ្រនាប់ | សាងសង់ប៉ុស្តិ៍យាមល្បាត | ៣ស្ថានីយ | ១.២០០ | ៣.៦០០ |
| | អ្នកល្បាត | ០៦នាក់/៣ស្ថានីយ៍ | ១៥០/៦នាក់/៨ខែ | ៧.២០០ |
| | សរុប | | | ១០.៨០០ |

១៤. យោងតាមតារាង៨-២ខាងលើ **ថវិកាសម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន** ក្នុង១ឆ្នាំៗមានចំនួន ២៣.២០០ដុល្លាអាមេរិក។ ក្រុមហ៊ុនបែងចែកការប្រើប្រាស់ថវិកានេះជាបួនចំណែក៖ (១) ថវិកាចំនួន ៣.៦០០ដុល្លាអាមេរិក/ឆ្នាំ សម្រាប់ផ្ដល់បៀវត្សចំពោះអ្នកសម្របសម្រួលបរិស្ថាន (LEC) ចំនួន ០១នាក់ (៣០០ដុល្លារក្នុងមួយខែ) (២) ថវិកាចំនួន ៦.០០០ដុល្លា/ឆ្នាំ សម្រាប់មន្ត្រីជំនាញនៃក្រសួងបរិស្ថានចុះត្រួតពិនិត្យ វាយតម្លៃការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុន (១.៥០០ដុល្លារ/ត្រីមាស) (៣) ថវិកាចំនួន ១០.០០០ដុល្លារអាមេរិក/ឆ្នាំ សម្រាប់មន្ត្រីជំនាញនៃក្រសួងបរិស្ថាន និងគណៈកម្មការអន្តរក្រសួងចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុន (៥.០០០ដុល្លារ/ឆមាស) និង (៤) ថវិកាចំនួន ៣.៦០០ដុល្លាអាមេរិកសម្រាប់ការធ្វើតេស្តចាំបាច់ផ្សេងៗ (១.៨០០ដុល្លារ/ឆមាស) (សូមមើលតារាង៨-២ ខាងលើ)។

**ដ្យាក្រាម៨.១៖ តម្លៃសរុបសម្រាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថាន ការត្រួតពិនិត្យ និងវាយតម្លៃតាមដាន**



## ៨-៣-៥ គម្រោងថវិកាសម្រាប់ការអភិវឌ្ឍន៍សហគមន៍ និងស្តារគុណភាពបរិស្ថាន

**១៥.** ចាប់ពីឆ្នាំ ២០១៥តទៅ ក្រុមហ៊ុនបានគ្រោងថវិកាសរុបចំនួន **៥៥.០០០.០០**ដុល្លារអាមេរិកក្នុងមួយឆ្នាំៗ សម្រាប់ការអភិវឌ្ឍន៍សហគមន៍ និងស្តារគុណភាពបរិស្ថាន ដែលមានរយៈពេលស្មើនឹងអាយុកាលនៃការធ្វើវិនិយោគ កំណត់ដោយច្បាប់ និងប្រើសម្រាប់: (១) អភិវឌ្ឍន៍សហគមន៍ចំនួន **២៥.០០០,០០**ដុល្លារអាមេរិក (២) ស្តារគុណភាពបរិស្ថានចំនួន ៣០.០០០,០០ដុល្លារអាមេរិក (សូមមើលតារាង ៨-៤)។

**តារាង ៨-៤៖ ថវិកាសរុបសម្រាប់អភិវឌ្ឍន៍សហគមន៍ និងស្តារគុណភាពបរិស្ថាន**

| កម្មវិធី | សកម្មភាព | ចំនួន | តម្លៃ (ដុល្លារ) | |
|---|---|---|---|---|
| | | | ឯកតា | សរុប |
| ថវិកាសម្រាប់សង្គម និងបរិស្ថាន | ថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍ | ០១ឆ្នាំ | ២៥.០០០ | ២៥.០០០ |
| | ថវិកាសម្រាប់ស្តារគុណភាពបរិស្ថាន | ០១ឆ្នាំ | ៣០.០០០ | ៣០.០០០ |
| | សរុប | | | **៥៥.០០០** |

**១៦.** យោងតាមតារាង៨-៤ខាងលើ **ថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍** ក្នុង១ឆ្នាំៗមានចំនួន ២៥.០០០ដុល្លារអាមេរិក។ សម្រាប់ឆ្នាំ ២០១៥ ក្រុមហ៊ុនដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) បែងចែកថវិកានេះជាពីរចំណែក៖ (១) ថវិកាចំនួន ២០.០០០ដុល្លារ ដើម្បីសាងសង់អណ្តូងទឹកដែលបំពាក់ដោយប្រព័ន្ធចែកចាយ និងបន្ទះសូឡាទាញយកថាមពលព្រះអាទិត្យមកប្រើប្រាស់សម្រាប់បូមទឹក (១០.០០០ដុល្លារ/អណ្តូង) នៅក្នុងភូមិចំនួនពីរ គឺភូមិឧបសម្ព័ន្ធស្រែនន និងភូមិស្វាយជ្រុំ (២) ថវិកាចំនួន ៥.០០០ដុល្លា ដើម្បីជួសជុលផ្លូវលំក្នុងភូមិស្វាយជ្រុំ (ដ្យាក្រាម៨-២)។

**១៧.** ចាប់ពីឆ្នាំ ២០១៦ ទៅទល់នឹងឆ្នាំ ២០១៩ ក្រុមហ៊ុនដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) គ្រោងនឹងបែងចែកថវិកានេះជាពីរចំណែក៖ (១) ថវិកាចំនួន ២០.០០០ដុល្លារ ដើម្បីសាងសង់អណ្តូងទឹកដែលបំពាក់ដោយប្រព័ន្ធចែកចាយ និងបន្ទះសូឡាទាញយកថាមពលព្រះអាទិត្យមកប្រើប្រាស់សម្រាប់បូមទឹក (១០.០០០ដុល្លារ/អណ្តូង) នៅក្នុងភូមិចំនួនពីរ ដែលជាភូមិអាទិភាពតាមការស្នើសុំរបស់ក្រុមប្រឹក្សាភូមិ និងឃុំ (២) ថវិកាចំនួន ៥.០០០ដុល្លារ ដើម្បីជួសជុលផ្លូវលំក្នុងភូមិអាទិភាពតាមការស្នើសុំរបស់ក្រុមប្រឹក្សាភូមិ និងឃុំ (ដ្យាក្រាម៨-២)។

Draft

ដ្យាក្រាម៨-២៖ ថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍ក្នុងឆ្នាំ២០១៥-២០១៩




**១៨.** ចាប់ពីឆ្នាំ ២០២០ តទៅជារៀងរាល់ឆ្នាំ ក្រុមហ៊ុនដូទីសាយហ្គូន-ប៊ិញហ្វៀក (អេស ប៊ី ខេ) គ្រោងនឹងបែងចែកថវិកានេះជាពីរចំណែក៖ (១) ថវិកាចំនួន ២០.០០០ដុល្លារ សម្រាប់សំណើអាទិភាពតាមការស្នើសុំរបស់ក្រុមប្រឹក្សាភូមិ និងឃុំ (២) ថវិកាចំនួន ៥.០០០ដុល្លារជាមូលនិធិអាហារូបករណ៍សម្រាប់និស្សិតដែលប្រលងជាប់មធ្យមសិក្សាទុតិយភូមិ ហើយមានបំណងបន្តការសិក្សានៅមហាវិទ្យាល័យ ប៉ុន្តែខ្វះខាតថវិកា ទៅតាមការស្នើសុំរបស់ក្រុមប្រឹក្សាភូមិ និងឃុំ (ដ្យាក្រាម៨-៣)។

ដ្យាក្រាម៨-៣៖ ថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍ចាប់ពីឆ្នាំ២០២០តរៀងទៅ




Draft

**១៩.** ដើម្បីទទួលបាននូវថវិកាសម្រាប់អភិវឌ្ឍន៍សហគមន៍ដូចបានរៀបរាប់ខាងលើ អាជ្ញាធរឃុំកន្ទួត និងឃុំថ្មី ត្រូវលើកជាសំណើ និងផ្តល់នូវផែនការអភិវឌ្ឍន៍ថ្នាក់ឃុំ ដែលជាលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់គ្នានៅថ្នាក់មូលដ្ឋាន មកក្រុមហ៊ុនតាមរយៈអាជ្ញាធរស្រុក ទីចាត់ការផែនការវិនិយោគខេត្ត មន្ទីរធនធានទឹក និងឧតុនិយមខេត្ត ដោយចាំបាច់ត្រូវមានការឆ្លង និងទទួលបានការឯកភាពពីគណៈនៃគណៈអភិបាលខេត្តក្រចេះជាមុនសិន។ ក្រុមហ៊ុន ដូទីសាយហ្គន-បិញហ្វៀក (អេស ប៊ី ខេ) មានភារៈកិច្ចផ្តល់នូវថវិកានៃមូលនិធិអភិវឌ្ឍន៍សហគមន៍របស់ខ្លួនសម្រាប់គម្រោងនេះ។ ការងារសាងសង់អណ្តូងទឹក និងការងារបច្ចេកទេសតបណ្តាញចែកចាយជាភារកិច្ចរបស់មន្ទីរធនធានទឹក និងឧតុនិយមខេត្ត។

**២០.** យោងតាមតារាង៨-៤ខាងលើ **ថវិកាសម្រាប់ស្តារគុណភាពបរិស្ថាន** ក្នុង១ឆ្នាំៗមានចំនួន ៣០.០០០ ដុល្លាអាមេរិក។ ក្រុមហ៊ុនដូទីសាយហ្គន-បិញហ្វៀក (អេស ប៊ី ខេ) គ្រោងនឹងបែងចែកថវិកានេះជាបួនចំណែក៖ (១) ថវិកាចំនួន ១០.០០០ដុល្លារជូនទៅក្រសួងបរិស្ថាន សម្រាប់រៀបចំកម្មវិធីដាំកូនឈើនៅក្នុងព្រៃរក្សាទុកដែលរេចរឹលនៃតំបន់ដីសម្បទាន នៅថ្ងៃបុណ្យជាតិរុក្ខទិវា (២) ថវិកាចំនួន ១០.០០០ដុល្លារ សម្រាប់ការងារបណ្តុះនិងថែទាំកូនឈើប្រភេទឈើទាល ផ្ចឿក និងគគីរចំនួន ៥.០០០ដើម/ឆ្នាំ ដែលក្រុមហ៊ុនខ្លួនឯងជាអ្នកទទួលអនុវត្តន៍ (៣) ថវិកាចំនួន ៥.០០០ដុល្លារជូនទៅក្រសួងបរិស្ថាន សម្រាប់អនុវត្តន៍ផែនការបណ្តុះបណ្តាលអភិវឌ្ឍន៍ធនធានមនុស្ស និង (៤) ថវិកាចំនួន ៥.០០០ដុល្លអាមេរិកជូនទៅមន្ទីរបរិស្ថានខេត្តក្រចេះ សម្រាប់អនុវត្តន៍ផែនការបណ្តុះបណ្តាលអភិវឌ្ឍន៍ធនធានមនុស្ស (ដ្យាក្រាម៨-៤)។

**ដ្យាក្រាម៨-៤៖ ថវិកាប្រចាំឆ្នាំសម្រាប់ស្តារគុណភាពបរិស្ថាន**




Draft

**២១.** ដើម្បីទទួលបាននូវថវិកាចំនួន ១០.០០០ដុល្លាអាមេរិក/ឆ្នាំ សម្រាប់រៀបចំកម្មវិធីដាំកូនឈើនៅក្នុងព្រៃរក្សាទុកនៃតំបន់ដីសម្បទានរបស់ក្រុមហ៊ុននៅថ្ងៃបុណ្យជាតិរុក្ខទិវា ជារៀងរាល់ឆ្នាំ ក្រសួងបរិស្ថាននឹងត្រូវជូនដំណឹង និងផ្តល់នូវផែនការសកម្មភាពនៃកម្មវិធីនេះ ទៅក្រុមហ៊ុន ដូទីសាយហ្គន-បិញហ្សៀក (អេស ប៊ី ខេ) ឲ្យបានយ៉ាងតិច ១សប្តាហ៍មុនថ្ងៃប្រារព្ធពិធី។ ហើយដើម្បីទទួលបាននូវថវិកាចំនួន ៥.០០០ដុល្លាអាមេរិក សម្រាប់អនុវត្តន៍ផែនការបណ្តុះបណ្តាលអភិវឌ្ឍន៍ធនធានមនុស្ស ជារៀងរាល់ឆ្នាំ ក្រសួងបរិស្ថានក៏ដូចជាមន្ទីរបរិស្ថានខេត្តក្រចេះ នឹងត្រូវផ្តល់នូវផែនការអភិវឌ្ឍន៍ធនធានមនុស្សប្រចាំឆ្នាំរៀងៗខ្លួន ទៅក្រុមហ៊ុនដូទីសាយហ្គន-បិញហ្សៀក(អេស ប៊ី ខេ) ឲ្យបានយ៉ាងតិច ២សប្តាហ៍មុនដំណាច់ឆ្នាំនីមួយៗ។